**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង-ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត និងបំពេញបន្ថែម អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សរសេរកាត់ថា "**ប.គ.ហ.**" ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាចីរភាព និងប្រសិទ្ធភាពដល់ដំណើរការ និងការគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងការសម្របសម្រួល ដើម្បីគោលដៅសុខដុមនីយកម្ម និង/ឬ សមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលប្រើប្រាស់នៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា។

## ជំពូកទី២

## បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២.-**

**ប.គ.ហ.** បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបេសកកម្មដឹកនាំ និងគ្រប់គ្រងការងារធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ដោយឈរលើមូលដ្ឋាននៃការរៀបចំយុទ្ធសាស្ត្រ ផែនការ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងការគាំទ្រដល់ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យកាន់តែរឹងមាំ មានគោលជំហរ និងទិសដៅឆ្ពោះទៅកាន់ស្តង់ដាឧត្តមានុវត្តន៍។

**មាត្រា៣.-**

**ប.គ.ហ.** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងចាត់ចែងលើកិច្ចការងាររដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ដំណើរប្រព្រឹត្តិទៅរបស់អគ្គនាយកដ្ឋាន និងទ្រទ្រង់ដល់ចីរភាពនៃការអនុវត្តគម្រោង និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងពាក់ព័ន្ធនានាដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងលើការងារអភិវឌ្ឍ កែលម្អ ថែទាំ និងនវានុវត្តប្រព័ន្ធដែលស្ថិតក្នុងវិសាលភាពនៃគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា
- ដឹកនាំជំរុញឱ្យសម្រេចបាននូវលក្ខខណ្ឌគ្រឹះនានា ក្នុងការទ្រទ្រង់ដល់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព

- ចូលរួមសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលស្ថិតក្នុងវិសាលភាពទំនើបកម្ម និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ
- ធានាចីរភាពដល់ដំណើរការ ភាពសុខដុម សង្គតិភាព និងសមាហរណកម្មនៃការប្រើប្រាស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងសម្របសម្រួលជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធ
- គ្រប់គ្រង និងតាមដានការរៀបចំ និងអនុវត្តផែនការ ការធានាគុណភាព និងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំ និងគ្រប់គ្រងកិច្ចលទ្ធកម្ម និងកិច្ចសន្យានានាដែលទ្រទ្រង់ដល់ការរៀបចំ កសាង និងដាក់ឱ្យដំណើរការ និងការពង្រីកវិសាលភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធដែលអនុវត្តដោយអគ្គនាយកដ្ឋានស្របតាមបទប្បញ្ញត្តិជាធរមាន
- ដឹកនាំ និងសម្របសម្រួលក្នុងការរៀបចំនីតិវិធីអនុវត្តការងារ និងការងារគ្រប់គ្រងការផ្លាស់ប្តូរ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធនានា
- រៀបចំផែនការ និងអនុវត្តការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដើម្បីទ្រទ្រង់ដល់ដំណើរការ និងបច្ចុប្បន្នភាពនៃការប្រើប្រាស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងចីរភាព
- គ្រប់គ្រង និងរៀបចំផ្នែកបច្ចេកទេសអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធី ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញតភ្ជាប់ ព្រមទាំងផ្នែកគាំទ្រដល់ការប្រើប្រាស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំ និងពង្រឹង គោលនយោបាយបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន នវានុវត្តន៍ និងសុវត្ថិភាពរបស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- តាមដាន ទ្រទ្រង់ និងផ្តល់សេវាថែទាំ ជួសជុល និងផ្លាស់ប្តូរជាថ្មីនូវ ឧបករណ៍ សម្ភារៈ បណ្តាញបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ប្រចាំត្រីមាស និងឆ្នាំ ឬតាមតម្រូវការចាំបាច់ជូនដល់គ្រប់ការដ្ឋានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំគ្រោងថវិកា ទាំងថវិកាចរន្ត និងថវិកាវិនិយោគ ដើម្បីធានាដល់ដំណើរការឥតដាច់នៃប្រព័ន្ធ ទាំងផ្នែកមុខងារ បច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ និងផ្នែកសុវត្ថិភាពរបស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល
- សម្របសម្រួលជាមួយក្រុមការងារផ្សេងៗ នៅតាមអង្គភាព ស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការសម្រេចឱ្យបានតាមគោលដៅនូវផែនការសកម្មភាពរបស់គម្រោងនានា ដែលអគ្គនាយកដ្ឋានបានដាក់ចេញតាមការសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចូលរួម និងផ្តល់កិច្ចសហប្រតិបត្តិការក្នុងសកម្មភាពគាំទ្រដល់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសកិច្ចសហប្រតិបត្តិការលើការងារបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈ ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ
- បំពេញតួនាទី និងភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៤.-**

**ប.គ.ហ.** មាននាយកដ្ឋានក្រោមឱវាទចំនួន ៣ ដូចខាងក្រោម៖

- នាយកដ្ឋានផែនការ និងកិច្ចការទូទៅ
- នាយកដ្ឋានគ្រប់គ្រងធុរកិច្ច
- នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន។

នាយកដ្ឋាននីមួយៗនៃ **ប.គ.ហ.** មានការិយាល័យក្រោមឱវាទមួយចំនួនតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យក្រោមឱវាទនាយកដ្ឋាននីមួយៗ នៃ **ប.គ.ហ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អង្គការលេខរបស់ **ប.គ.ហ.** ត្រូវកំណត់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**ប.គ.ហ.** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ដើម្បីបំពេញការងាររបស់ខ្លួន។

**មាត្រា៥.-**

នាយកដ្ឋានផែនការ និងកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យ **ប.គ.ហ.** លើការងាររដ្ឋបាល ការរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ ផែនការ ផែនការសកម្មភាព ធនធានមនុស្ស និងហិរញ្ញវត្ថុ ការគ្រប់គ្រងសារពើភណ្ឌ ការគាំទ្រទូទៅ និងការគ្រប់គ្រងគុណភាពលើគម្រោងនានារបស់អគ្គនាយកដ្ឋាន។ នាយកដ្ឋានផែនការ និងកិច្ចការទូទៅ មានភារកិច្ចជាអាទិ៍ ៖

- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ និងសមិទ្ធផលរបស់អគ្គនាយកដ្ឋានជាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ និងគាំទ្រដល់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា
- គ្រប់គ្រង និងចាត់ចែងលើកិច្ចការងាររដ្ឋបាល ការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ដំណើរប្រព្រឹត្តិទៅរបស់អគ្គនាយកដ្ឋាន និងទ្រទ្រង់ដល់ចីរភាពនៃការអនុវត្តគម្រោង និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងពាក់ព័ន្ធដែលអនុវត្តដោយអគ្គនាយកដ្ឋាន
- គ្រប់គ្រង និងតាមដានការរៀបចំ និងអនុវត្តផែនការនានារបស់អគ្គនាយកដ្ឋានរួមមាន គោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការធនធានមនុស្ស និងផែនការថវិកាដែលពាក់ព័ន្ធនឹងការងារគម្រោង និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រងដល់ការធានាគុណភាព និងបញ្ចៀសហានិភ័យនានាពាក់ព័ន្ធនឹងការងារគម្រោង និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលអនុវត្តដោយអគ្គនាយកដ្ឋាន
- រៀបចំ គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្ម និងកិច្ចសន្យានានាដែលទ្រទ្រង់ដល់ការរៀបចំ កសាង និងដាក់ឱ្យដំណើរការការពង្រីកវិសាលភាព និងការពង្រឹងសមត្ថភាព និងសុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធដែលអនុវត្តដោយអគ្គនាយកដ្ឋានស្របតាមបទប្បញ្ញត្តិជាធរមាន

- ចូលរួមសហការ រៀបចំ និងពង្រឹងការអនុវត្តគោលនយោបាយបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន ឌីជីថលូបនីយកម្ម នវានុវត្តន៍ និងសុវត្ថិភាពរបស់ប្រព័ន្ធទាំងអស់ដែលស្ថិតនៅក្នុងគម្រោង និងប្រព័ន្ធអនុវត្តដោយអគ្គនាយកដ្ឋាន និងការងារពាក់ព័ន្ធទៅនឹងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការចាត់តាំង ឬប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំគ្រោងថវិកា ទាំងថវិកាចរន្ត និងថវិកាវិនិយោគ ដើម្បីធានាដល់ដំណើរការឥតដាច់នៃប្រព័ន្ធ ទាំងផ្នែកមុខងារ បច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍បណ្តាញតភ្ជាប់ និងផ្នែកសុវត្ថិភាពរបស់ប្រព័ន្ធទាំងមូលដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋាន
- រៀបចំផែនការ យន្តការ និងធនធានមនុស្សក្នុងការផ្តល់ការគាំទ្រផ្នែកមុខងារប្រព័ន្ធ កម្មវិធី និងផ្នែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍កម្រិតដំបូង(កម្រិតទី១) ជូនដល់អ្នកប្រើប្រាស់ប្រព័ន្ធនានាដែលផ្តល់ជូនដោយអគ្គនាយកដ្ឋាន តាមរយៈការប្រើប្រាស់មជ្ឈមណ្ឌលគាំទ្រអ្នកប្រើប្រាស់ និងបណ្តាញទំនាក់ទំនងផ្លូវការនានារបស់ប្រព័ន្ធ
- គ្រប់គ្រង តាមដាន និងពង្រឹងដល់ការអនុវត្តចំណាយថវិការបស់នាយកដ្ឋាន និងអង្គភាពស្ថិតក្រោមឱវាទរបស់អគ្គនាយកដ្ឋាន ជាមួយនឹងការគ្រប់គ្រងចំណូលថវិកាដែលអគ្គនាយកដ្ឋានប្រមូលបានឱ្យមានគណនេយ្យភាពស្របតាមបទប្បញ្ញត្តិជាធរមាន
- សម្របសម្រួលជាមួយក្រុមការងារផ្សេងៗ នៅតាមអង្គភាពស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការសម្រេចឱ្យបានតាមគោលដៅនូវផែនការសកម្មភាពរបស់គម្រោងនានា ដែលអគ្គនាយកដ្ឋានបានដាក់ចេញ
- ចូលរួម និងផ្តល់កិច្ចសហប្រតិបត្តិការក្នុងសកម្មភាពគាំទ្រដល់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់ពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសកិច្ចសហប្រតិបត្តិការលើការងារបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈ ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ
- បំពេញតួនាទី និងភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន។

**មាត្រា៦.-**

នាយកដ្ឋានគ្រប់គ្រងធុរកិច្ច បំពេញមុខងារជាសេនាធិការឱ្យ **ប.គ.ហ.** លើការងារគ្រប់គ្រងមុខងារកម្មវិធី និងប្រព័ន្ធ វិភាគធុរកិច្ច និងផលប៉ះពាល់ គ្រប់គ្រងការផ្លាស់ប្តូរ រៀបចំផែនការ និងសហការផ្តល់ការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងការផ្សព្វផ្សាយលើការងារពាក់ព័ន្ធនឹងការអនុវត្តគម្រោងនានារបស់អគ្គនាយកដ្ឋាន។ នាយកដ្ឋានគ្រប់គ្រងធុរកិច្ច មានភារកិច្ចជាអាទិ៍ ៖

- គ្រប់គ្រង រៀបចំ និងអនុវត្តលើកិច្ចការងារអភិវឌ្ឍ កែលម្អ ច្នៃប្រឌិត និងនវានុវត្តប្រព័ន្ធនានា ដែលអនុវត្តដោយអគ្គនាយកដ្ឋាន
- ដឹកនាំលើការជំរុញ និងរៀបចំការងារឱ្យសម្រេចបាននូវលក្ខខណ្ឌគ្រឹះនានា ក្នុងការទ្រទ្រង់ដល់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព
- ដឹកនាំ និងសម្របសម្រួលការរៀបចំនីតិវិធីអនុវត្តការងារ ស្តង់ដានីតិវិធី សេចក្តីណែនាំ និងឯកសារនានា ដើម្បីទ្រទ្រង់ដល់ការតម្រឹម និងតម្រង់ទិសនីតិវិធីអនុវត្តការងារក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធទាំងឡាយដែលអនុវត្តដោយអគ្គនាយកដ្ឋាន ឱ្យអាចឈាន ឆ្ពោះទៅកាន់ស្តង់ដាឧត្តមានុវត្តន៍

- រៀបចំផែនការ និងជំរុញការអនុវត្តការងារគ្រប់គ្រងការផ្លាស់ប្តូរ ដើម្បីទ្រទ្រង់ដល់ដំណើរការរបស់ប្រព័ន្ធ និងគម្រោងនានាដែលអនុវត្តដោយអគ្គនាយកដ្ឋាន សហការយ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធទាំងអស់
- រៀបចំផែនការ និងយន្តការវាយតម្លៃលើផលប៉ះពាល់ជាប្រចាំលើការអនុវត្តគម្រោង និងប្រើប្រាស់ប្រព័ន្ធនានាដែលអគ្គនាយកដ្ឋានបានអនុវត្តទៅកាន់ការដ្ឋាននៃគម្រោងនីមួយៗ
- រៀបចំផែនការ ផែនការសកម្មភាព និងយន្តការ ដើម្បីធានាចីរភាពដល់ដំណើរការ ភាពសុខដុម សង្គតិភាព និងសមាហរណកម្មនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការ និងអនុវត្តការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដើម្បីទ្រទ្រង់ដល់ដំណើរការ និងបច្ចុប្បន្នភាពនៃការប្រើប្រាស់ប្រព័ន្ធប្រកបដោយប្រសិទ្ធភាព និងចីរភាព
- ផ្តល់នូវធនធានមនុស្សសម្រាប់ចូលរួមដល់វគ្គបណ្តុះបណ្តាល និងកសាងសមត្ថភាពនានា ស្ថិតនៅក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការងារស្នូលរបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការ យន្តការ និងមធ្យោបាយ លើការងារគ្រប់គ្រងការផ្លាស់ប្តូរ ផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងជូនអ្នកពាក់ព័ន្ធ និងសាធារណជន និងពង្រឹងទំនាក់ទំនងសាធារណៈសម្រាប់ការងាររបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការ យន្តការ និងធនធានមនុស្សក្នុងការផ្តល់ការគាំទ្រផ្នែកមុខងារប្រព័ន្ធកម្រិតទី២ ជូនដល់អ្នកប្រើប្រាស់ប្រព័ន្ធនានាដែលផ្តល់ជូនដោយអគ្គនាយកដ្ឋាន តាមរយៈការប្រើប្រាស់មជ្ឈមណ្ឌលគាំទ្រអ្នកប្រើប្រាស់ និងបណ្តាញទំនាក់ទំនងផ្លូវការនានារបស់ប្រព័ន្ធ
- បំពេញតួនាទី និងភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន។

**មាត្រា៧.-**

នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យ **ម.គ.ហ.** លើការងារអភិវឌ្ឍ ច្នៃប្រឌិត បង្កើតថ្មី និងនវានុវត្តលើកម្មវិធី និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការរៀបចំ ដំឡើង និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបណ្តាញតភ្ជាប់ និងការគ្រប់គ្រងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានរបស់ប្រព័ន្ធនានាដែលអនុវត្តដោយអគ្គនាយកដ្ឋាន។ នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន មានភារកិច្ចជាអាទិ៍ ៖

- គ្រប់គ្រង និងរៀបចំការអភិវឌ្ឍកម្មវិធី និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការធ្វើសមាហរណកម្ម និងសន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ទ្រទ្រង់ដល់វិស័យហិរញ្ញវត្ថុសាធារណៈ
- អភិវឌ្ឍ និងធ្វើនវានុវត្តនូវមុខងារ និងតម្រូវការកម្មវិធីចាំបាច់បន្ថែមសម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ច្នៃប្រឌិត និងបង្កើតវិធីសាស្ត្រ នីតិវិធី កម្មវិធី និងប្រព័ន្ធថ្មីៗ ដើម្បីគាំទ្រ និងទ្រទ្រង់ដល់ដំណើរការគ្រប់គ្រង និងអនុវត្តថវិកាជាតិឱ្យកាន់តែប្រសើរឡើង

- ផ្តល់សេវា ដំឡើង ទ្រទ្រង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបណ្តាញតភ្ជាប់ រួមទាំងមជ្ឈមណ្ឌលទិន្នន័យ និងសេវាទំនាក់ទំនងផ្សេងៗដូចជា សារអេឡិចត្រូនិក អ៊ីនធឺណិត និងឧបករណ៍ទំនាក់ទំនងផ្សេងៗ ជូនដល់ការដ្ឋានទាំងអស់របស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងនានាដែលអនុវត្តដោយអគ្គនាយកដ្ឋាន
- រៀបចំផែនការ យុទ្ធសាស្ត្រ ឯកសារគោលនយោបាយ ស្តង់ដា នីតិវិធី និងផែនការសកម្មភាពក្នុងការ-ពង្រឹងផ្នែកសុវត្ថិភាពនៃការប្រើប្រាស់ប្រព័ន្ធនានាដែលអនុវត្តដោយអគ្គនាយកដ្ឋាន និងការពង្រឹងសមត្ថភាពផ្នែកសន្តិសុខទិន្នន័យ និងសុវត្ថិភាពជូនដល់អគ្គនាយកដ្ឋាន
- តាមដាន ទ្រទ្រង់ និងផ្តល់សេវាថែទាំ ជួសជុល និងផ្លាស់ប្តូរជាថ្មីនូវ ឧបករណ៍ សម្ភារៈ និងបណ្តាញបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ប្រចាំត្រីមាស និងឆ្នាំ ឬតាមតម្រូវការចាំបាច់ជូនដល់គ្រប់ការដ្ឋានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធនានាដែលបានផ្តល់ជូនដោយអគ្គនាយកដ្ឋាន
- រៀបចំការស្រាវជ្រាវលើបច្ចេកវិទ្យាថ្មីៗទៅតាមនិន្នាការវិវត្តនៃបច្ចេកវិទ្យាជាសកល ដើម្បីទ្រទ្រង់ដល់ការធ្វើទំនើបកម្មនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យបានដើរទាន់សភាពការណ៍ និងការរីកចម្រើននៃសង្គម-សេដ្ឋកិច្ចកម្ពុជា
- កំណត់ផែនទីចង្អុលផ្លូវ ផែនការ និងយន្តការធានាចីរភាពនៃការអភិវឌ្ឍកម្មវិធី និងប្រព័ន្ធនានា ដែលអនុវត្តដោយអគ្គនាយកដ្ឋាន ធានាមិនឱ្យស្ថិតនៅក្នុងគំនាប ឬហានិភ័យដោយថាហេតុណាមួយរហូតដល់មានការអាក់ខានដល់ការធ្វើប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ
- រៀបចំផែនការ យន្តការ និងធនធានមនុស្សក្នុងការផ្តល់ការគាំទ្រផ្នែកកម្មវិធី និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍កម្រិតទី២ ជូនដល់អ្នកប្រើប្រាស់ប្រព័ន្ធនានាដែលផ្តល់ជូនដោយអគ្គនាយកដ្ឋាន តាមរយៈការប្រើប្រាស់មជ្ឈមណ្ឌលគាំទ្រអ្នកប្រើប្រាស់ និងបណ្តាញទំនាក់ទំនងផ្លូវការនានារបស់ប្រព័ន្ធ
- បំពេញតួនាទី និងភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន។

**មាត្រា៨.-**

**ប.គ.ហ.** មានប្រភពធនធានថវិកាផ្គត់ផ្គង់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ អគ្គនាយកដ្ឋាន ក៏មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ និងថវិកាដែលបានមកពីការផ្តល់សេវាពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់ខ្លួន និងហិរញ្ញប្បទានសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងពីប្រភពស្របច្បាប់ផ្សេងៗទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៩.-**

**ប.គ.ហ.** ត្រូវដឹកនាំដោយអគ្គនាយក ១ (មួយ) រូប និងអមដោយអគ្គនាយករង មួយចំនួន អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នាយកដ្ឋាននីមួយៗនៃ **ប.គ.ហ.** ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប និងអមដោយអនុប្រធានមួយចំនួន អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៥៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង-ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត និងបំពេញបន្ថែម អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សរសេរកាត់ថា "**ប.គ.ហ.**" ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាចីរភាព និងប្រសិទ្ធភាពដល់ដំណើរការ និងការគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងការសម្របសម្រួល ដើម្បីគោលដៅសុខដុមនីយកម្ម និង/ឬ សមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលប្រើប្រាស់នៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា។

## ជំពូកទី២
## បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២.-**

**ប.គ.ហ.** បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបេសកកម្មដឹកនាំ និងគ្រប់គ្រងការងារធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ដោយឈរលើមូលដ្ឋាននៃការរៀបចំយុទ្ធសាស្ត្រ ផែនការ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងការគាំទ្រដល់ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យកាន់តែរឹងមាំ មានគោលជំហរ និងទិសដៅឆ្ពោះទៅកាន់ស្តង់ដាឧត្តមានុវត្តន៍។

**មាត្រា៣.-**

**ប.គ.ហ.** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងចាត់ចែងលើកិច្ចការងាររដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ដំណើរប្រព្រឹត្តិទៅរបស់អគ្គនាយកដ្ឋាន និងទ្រទ្រង់ដល់ចីរភាពនៃការអនុវត្តគម្រោង និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងពាក់ព័ន្ធនានាដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងលើការងារអភិវឌ្ឍ កែលម្អ ថ្វៃប្រឌិត និងនវានុវត្តប្រព័ន្ធដែលស្ថិតក្នុងវិសាលភាពនៃគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា
- ដឹកនាំជំរុញឱ្យសម្រេចបាននូវលក្ខខណ្ឌគ្រឹះនានា ក្នុងការទ្រទ្រង់ដល់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព

- ចូលរួមសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលស្ថិតក្នុងវិសាលភាពទំនើបកម្ម និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ
- ធានាចីរភាពដល់ដំណើរការ ភាពសុខដុម សង្គតិភាព និងសមាហរណកម្មនៃការប្រើប្រាស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងសម្របសម្រួលជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធ
- គ្រប់គ្រង និងតាមដានការរៀបចំ និងអនុវត្តផែនការ ការធានាគុណភាព និងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំ និងគ្រប់គ្រងកិច្ចលទ្ធកម្ម និងកិច្ចសន្យានានាដែលទ្រទ្រង់ដល់ការរៀបចំ កសាង និងដាក់ឱ្យដំណើរការ និងការពង្រីកវិសាលភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធដែលអនុវត្តដោយអគ្គនាយកដ្ឋានស្របតាមបទប្បញ្ញត្តិជាធរមាន
- ដឹកនាំ និងសម្របសម្រួលក្នុងការរៀបចំនីតិវិធីអនុវត្តការងារ និងការងារគ្រប់គ្រងការផ្លាស់ប្តូរ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធនានា
- រៀបចំផែនការ និងអនុវត្តការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដើម្បីទ្រទ្រង់ដល់ដំណើរការ និងបច្ចុប្បន្នភាពនៃការប្រើប្រាស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងចីរភាព
- គ្រប់គ្រង និងរៀបចំផ្នែកបច្ចេកទេសអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធី ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញតភ្ជាប់ ព្រមទាំងផ្នែកគាំទ្រដល់ការប្រើប្រាស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំ និងពង្រឹង គោលនយោបាយបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន នវានុវត្តន៍ និងសុវត្ថិភាពរបស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- តាមដាន ទ្រទ្រង់ និងផ្តល់សេវាថែទាំ ជួសជុល និងផ្លាស់ប្តូរជាថ្មីនូវ ឧបករណ៍ សម្ភារៈ បណ្តាញបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ប្រចាំត្រីមាស និងឆ្នាំ ឬតាមតម្រូវការចាំបាច់ជូនដល់គ្រប់ការដ្ឋានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំគ្រោងថវិកា ទាំងថវិកាចរន្ត និងថវិកាវិនិយោគ ដើម្បីធានាដល់ដំណើរការឥតដាច់នៃប្រព័ន្ធ ទាំងផ្នែកមុខងារ បច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ និងផ្នែកសុវត្ថិភាពរបស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល
- សម្របសម្រួលជាមួយក្រុមការងារផ្សេងៗ នៅតាមអង្គភាព ស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការសម្រេចឱ្យបានតាមគោលដៅនូវផែនការសកម្មភាពរបស់គម្រោងនានា ដែលអគ្គនាយកដ្ឋានបានដាក់ចេញតាមការសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចូលរួម និងផ្តល់កិច្ចសហប្រតិបត្តិការក្នុងសកម្មភាពគាំទ្រដល់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសកិច្ចសហប្រតិបត្តិការលើការងារបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈ ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ
- បំពេញតួនាទី និងភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៤.-**

**ប.គ.ហ.** មាននាយកដ្ឋានក្រោមឱវាទចំនួន ៣ ដូចខាងក្រោម៖

- នាយកដ្ឋានផែនការ និងកិច្ចការទូទៅ
- នាយកដ្ឋានគ្រប់គ្រងធុរកិច្ច
- នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន។

នាយកដ្ឋាននីមួយៗនៃ **ប.គ.ហ.** មានការិយាល័យក្រោមឱវាទមួយចំនួនតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យក្រោមឱវាទនាយកដ្ឋាននីមួយៗ នៃ **ប.គ.ហ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អង្គការលេខរបស់ **ប.គ.ហ.** ត្រូវកំណត់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**ប.គ.ហ.** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ដើម្បីបំពេញការងាររបស់ខ្លួន។

**មាត្រា៥.-**

នាយកដ្ឋានផែនការ និងកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យ **ប.គ.ហ.** លើការងាររដ្ឋបាល ការរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ ផែនការ ផែនការសកម្មភាព ធនធានមនុស្ស និងហិរញ្ញវត្ថុ ការគ្រប់គ្រងសារពើភណ្ឌ ការគាំទ្រទូទៅ និងការគ្រប់គ្រងគុណភាពលើគម្រោងនានារបស់អគ្គនាយកដ្ឋាន។ នាយកដ្ឋានផែនការ និងកិច្ចការទូទៅ មានភារកិច្ចជាអាទិ៍ ៖

- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ និងសមិទ្ធផលរបស់អគ្គនាយកដ្ឋានជាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ និងគាំទ្រដល់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា
- គ្រប់គ្រង និងចាត់ចែងលើកិច្ចការងាររដ្ឋបាល ការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ដំណើរប្រព្រឹត្តិទៅរបស់អគ្គនាយកដ្ឋាន និងទ្រទ្រង់ដល់ចីរភាពនៃការអនុវត្តគម្រោង និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងពាក់ព័ន្ធដែលអនុវត្តដោយអគ្គនាយកដ្ឋាន
- គ្រប់គ្រង និងតាមដានការរៀបចំ និងអនុវត្តផែនការនានារបស់អគ្គនាយកដ្ឋានរួមមាន គោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការធនធានមនុស្ស និងផែនការថវិកាដែលពាក់ព័ន្ធនឹងការងារគម្រោង និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រងដល់ការធានាគុណភាព និងបញ្ចៀសហានិភ័យនានាពាក់ព័ន្ធនឹងការងារគម្រោង និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលអនុវត្តដោយអគ្គនាយកដ្ឋាន
- រៀបចំ គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្ម និងកិច្ចសន្យានានាដែលទ្រទ្រង់ដល់ការរៀបចំ កសាង និងដាក់ឱ្យដំណើរការការពង្រីកវិសាលភាព និងការពង្រឹងសមត្ថភាព និងសុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធដែលអនុវត្តដោយអគ្គនាយកដ្ឋានស្របតាមបទប្បញ្ញត្តិជាធរមាន

- ចូលរួមសហការ រៀបចំ និងពង្រឹងការអនុវត្តគោលនយោបាយបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន ឌីជីថលូប-នីយកម្ម នវានុវត្តន៍ និងសុវត្ថិភាពរបស់ប្រព័ន្ធទាំងអស់ដែលស្ថិតនៅក្នុងគម្រោង និងប្រព័ន្ធអនុវត្តដោយអគ្គនាយកដ្ឋាន និងការងារពាក់ព័ន្ធទៅនឹងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការចាត់តាំង ឬប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំគ្រោងថវិកា ទាំងថវិកាចរន្ត និងថវិកាវិនិយោគ ដើម្បីធានាដល់ដំណើរការឥតដាច់នៃប្រព័ន្ធ ទាំងផ្នែកមុខងារ បច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍បណ្តាញតភ្ជាប់ និងផ្នែកសុវត្ថិភាពរបស់ប្រព័ន្ធទាំងមូលដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋាន
- រៀបចំផែនការ យន្តការ និងធនធានមនុស្សក្នុងការផ្តល់ការគាំទ្រផ្នែកមុខងារប្រព័ន្ធ កម្មវិធី និងផ្នែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍កម្រិតដំបូង(កម្រិតទី១) ជូនដល់អ្នកប្រើប្រាស់ប្រព័ន្ធនានាដែលផ្តល់ជូនដោយអគ្គនាយកដ្ឋាន តាមរយៈការប្រើប្រាស់មជ្ឈមណ្ឌលគាំទ្រអ្នកប្រើប្រាស់ និងបណ្តាញទំនាក់ទំនងផ្លូវការនានារបស់ប្រព័ន្ធ
- គ្រប់គ្រង តាមដាន និងពង្រឹងដល់ការអនុវត្តចំណាយថវិការបស់នាយកដ្ឋាន និងអង្គភាពស្ថិតក្រោមឱវាទរបស់អគ្គនាយកដ្ឋាន ជាមួយនឹងការគ្រប់គ្រងចំណូលថវិកាដែលអគ្គនាយកដ្ឋានប្រមូលបានឱ្យមានគណនេយ្យភាពស្របតាមបទប្បញ្ញត្តិជាធរមាន
- សម្របសម្រួលជាមួយក្រុមការងារផ្សេងៗ នៅតាមអង្គភាពស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការសម្រេចឱ្យបានតាមគោលដៅនូវផែនការសកម្មភាពរបស់គម្រោងនានា ដែលអគ្គនាយកដ្ឋានបានដាក់ចេញ
- ចូលរួម និងផ្តល់កិច្ចសហប្រតិបត្តិការក្នុងសកម្មភាពគាំទ្រដល់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធា-រណៈ និងកម្មវិធីកែទម្រង់ពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសកិច្ចសហប្រតិបត្តិការលើការងារបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈ ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ
- បំពេញតួនាទី និងភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន។

**មាត្រា៦.-**

នាយកដ្ឋានគ្រប់គ្រងធុរកិច្ច បំពេញមុខងារជាសេនាធិការឱ្យ **ប.គ.ហ.** លើការងារគ្រប់គ្រងមុខងារកម្មវិធីនិងប្រព័ន្ធ វិភាគធុរកិច្ច និងផលប៉ះពាល់ គ្រប់គ្រងការផ្លាស់ប្តូរ រៀបចំផែនការ និងសហការផ្តល់ការបណ្តុះបណ្តាលការកសាងសមត្ថភាព និងការផ្សព្វផ្សាយលើការងារពាក់ព័ន្ធនឹងការអនុវត្តគម្រោងនានារបស់អគ្គនាយកដ្ឋាន។ នាយកដ្ឋានគ្រប់គ្រងធុរកិច្ច មានភារកិច្ចជាអាទិ៍ ៖

- គ្រប់គ្រង រៀបចំ និងអនុវត្តលើកិច្ចការងារអភិវឌ្ឍ កែលម្អ ច្នៃប្រឌិត និងនវានុវត្តប្រព័ន្ធនានា ដែលអនុវត្តដោយអគ្គនាយកដ្ឋាន
- ដឹកនាំលើការជំរុញ និងរៀបចំការងារឱ្យសម្រេចបាននូវលក្ខខណ្ឌគ្រឹះនានា ក្នុងការទ្រទ្រង់ដល់ការ-ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព
- ដឹកនាំ និងសម្របសម្រួលការរៀបចំនីតិវិធីអនុវត្តការងារ ស្តង់ដានីតិវិធី សេចក្តីណែនាំ និងឯកសារនានា ដើម្បីទ្រទ្រង់ដល់ការតម្រឹម និងតម្រង់ទិសនីតិវិធីអនុវត្តការងារក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធទាំងឡាយដែលអនុវត្តដោយអគ្គនាយកដ្ឋាន ឱ្យអាចឈានឆ្ពោះទៅកាន់ស្តង់ដាឧត្តមានុវត្តន៍

- រៀបចំផែនការ និងជំរុញការអនុវត្តការងារគ្រប់គ្រងការផ្លាស់ប្តូរ ដើម្បីទ្រទ្រង់ដល់ដំណើរការរបស់ប្រព័ន្ធ និងគម្រោងនានាដែលអនុវត្តដោយអគ្គនាយកដ្ឋាន សហការយ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធទាំងអស់
- រៀបចំផែនការ និងយន្តការវាយតម្លៃលើផលប៉ះពាល់ជាប្រចាំលើការអនុវត្តគម្រោង និងប្រើប្រាស់ប្រព័ន្ធនានាដែលអគ្គនាយកដ្ឋានបានអនុវត្តទៅកាន់ការដ្ឋាននៃគម្រោងនីមួយៗ
- រៀបចំផែនការ ផែនការសកម្មភាព និងយន្តការ ដើម្បីធានាចីរភាពដល់ដំណើរការ ភាពសុខដុម សង្គតិភាព និងសមាហរណកម្មនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការ និងអនុវត្តការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដើម្បីទ្រទ្រង់ដល់ដំណើរការ និងបច្ចុប្បន្នភាពនៃការប្រើប្រាស់ប្រព័ន្ធប្រកបដោយប្រសិទ្ធភាព និងចីរភាព
- ផ្តល់នូវធនធានមនុស្សសម្រាប់ចូលរួមដល់វគ្គបណ្តុះបណ្តាល និងកសាងសមត្ថភាពនានា ស្ថិតនៅក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការងារស្នូលរបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការ យន្តការ និងមធ្យោបាយ លើការងារគ្រប់គ្រងការផ្លាស់ប្តូរ ផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងជូនអ្នកពាក់ព័ន្ធ និងសាធារណជន និងពង្រឹងទំនាក់ទំនងសាធារណៈសម្រាប់ការងាររបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការ យន្តការ និងធនធានមនុស្សក្នុងការផ្តល់ការគាំទ្រផ្នែកមុខងារប្រព័ន្ធកម្រិតទី២ ជូនដល់អ្នកប្រើប្រាស់ប្រព័ន្ធនានាដែលផ្តល់ជូនដោយអគ្គនាយកដ្ឋាន តាមរយៈការប្រើប្រាស់មជ្ឈមណ្ឌលគាំទ្រអ្នកប្រើប្រាស់ និងបណ្តាញទំនាក់ទំនងផ្លូវការនានារបស់ប្រព័ន្ធ
- បំពេញតួនាទី និងភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន។

**មាត្រា៧.-**

នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យ **ប.គ.ហ.** លើការងារអភិវឌ្ឍ ច្នៃប្រឌិត បង្កើតថ្មី និងនវានុវត្តលើកម្មវិធី និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការរៀបចំ ដំឡើង និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបណ្តាញតភ្ជាប់ និងការគ្រប់គ្រងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានរបស់ប្រព័ន្ធនានាដែលអនុវត្តដោយអគ្គនាយកដ្ឋាន។ នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន មានភារកិច្ចជាអាទិ៍ ៖

- គ្រប់គ្រង និងរៀបចំការអភិវឌ្ឍកម្មវិធី និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការធ្វើសមាហរណកម្ម និងសន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ទ្រទ្រង់ដល់វិស័យហិរញ្ញវត្ថុសាធារណៈ
- អភិវឌ្ឍ និងធ្វើនវានុវត្តនូវមុខងារ និងតម្រូវការកម្មវិធីចាំបាច់បន្ថែមសម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ច្នៃប្រឌិត និងបង្កើតវិធីសាស្ត្រ នីតិវិធី កម្មវិធី និងប្រព័ន្ធថ្មីៗ ដើម្បីគាំទ្រ និងទ្រទ្រង់ដល់ដំណើរការគ្រប់គ្រង និងអនុវត្តថវិកាជាតិឱ្យកាន់តែប្រសើរឡើង

- ផ្តល់សេវា ដំឡើង ទ្រទ្រង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបណ្តាញតភ្ជាប់ រួមទាំងមជ្ឈមណ្ឌលទិន្នន័យ និងសេវាទំនាក់ទំនងផ្សេងៗដូចជា សារអេឡិចត្រូនិក អ៊ីនធឺណិត និងឧបករណ៍ទំនាក់ទំនងផ្សេងៗ ជូនដល់ការដ្ឋានទាំងអស់របស់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងនានាដែលអនុវត្តដោយអគ្គនាយកដ្ឋាន
- រៀបចំផែនការ យុទ្ធសាស្ត្រ ឯកសារគោលនយោបាយ ស្តង់ដា នីតិវិធី និងផែនការសកម្មភាពក្នុងការ-ពង្រឹងផ្នែកសុវត្ថិភាពនៃការប្រើប្រាស់ប្រព័ន្ធនានាដែលអនុវត្តដោយអគ្គនាយកដ្ឋាន និងការពង្រឹងសមត្ថភាពផ្នែកសន្តិសុខទិន្នន័យ និងសុវត្ថិភាពជូនដល់អគ្គនាយកដ្ឋាន
- តាមដាន ទ្រទ្រង់ និងផ្តល់សេវាថែទាំ ជួសជុល និងផ្លាស់ប្តូរជាថ្មីនូវ ឧបករណ៍ សម្ភារៈ និងបណ្តាញបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ប្រចាំត្រីមាស និងឆ្នាំ ឬតាមតម្រូវការចាំបាច់ជូនដល់គ្រប់ការដ្ឋានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធនានាដែលបានផ្តល់ជូនដោយអគ្គនាយកដ្ឋាន
- រៀបចំការស្រាវជ្រាវលើបច្ចេកវិទ្យាថ្មីៗទៅតាមនិន្នាការវិវត្តនៃបច្ចេកវិទ្យាជាសកល ដើម្បីទ្រទ្រង់ដល់ការធ្វើទំនើបកម្មនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យបានដើរទាន់សភាពការណ៍ និងការរីកចម្រើននៃសង្គម-សេដ្ឋកិច្ចកម្ពុជា
- កំណត់ផែនទីចង្អុលផ្លូវ ផែនការ និងយន្តការធានាចីរភាពនៃការអភិវឌ្ឍកម្មវិធី និងប្រព័ន្ធនានា ដែលអនុវត្តដោយអគ្គនាយកដ្ឋាន ជានាមិនឱ្យស្ថិតនៅក្នុងគំនាប ឬហានិភ័យជាយថាហេតុណាមួយរហូតដល់មានការអាក់ខានដល់ការធ្វើប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ
- រៀបចំផែនការ យន្តការ និងធនធានមនុស្សក្នុងការផ្តល់ការគាំទ្រផ្នែកកម្មវិធី និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍កម្រិតទី២ ជូនដល់អ្នកប្រើប្រាស់ប្រព័ន្ធនានាដែលផ្តល់ជូនដោយអគ្គនាយកដ្ឋាន តាមរយៈការប្រើប្រាស់មជ្ឈមណ្ឌលគាំទ្រអ្នកប្រើប្រាស់ និងបណ្តាញទំនាក់ទំនងផ្លូវការនានារបស់ប្រព័ន្ធ
- បំពេញតួនាទី និងភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន។

**មាត្រា៨.-**

**ប.គ.ហ.** មានប្រភពធនធានថវិកាផ្គត់ផ្គង់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ អគ្គនាយកដ្ឋាន ក៏មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ និងថវិកាដែលបានមកពីការផ្តល់សេវាពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់ខ្លួន និងហិរញ្ញប្បទានសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងពីប្រភពស្របច្បាប់ផ្សេងៗទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៩.-**

**ប.គ.ហ.** ត្រូវដឹកនាំដោយអគ្គនាយក ១ (មួយ) រូប និងអមដោយអគ្គនាយករង មួយចំនួន អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នាយកដ្ឋាននីមួយៗនៃ **ប.គ.ហ.** ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប និងអមដោយអនុប្រធានមួយចំនួន អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

# ជំពូកទី៣
# អវសានប្បញ្ញត្តិ

**មាត្រា១០.-**

អនុក្រឹត្យនេះត្រូវបំពេញបន្ថែមអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ**

**នៃអនុក្រឹត្យលេខ ២៥៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០២៣**

**ស្តីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អង្គការលេខរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**



**ឧបសម្ព័ន្ធ**

**នៃអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧**

**ស្តីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អង្គការលេខរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

